ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ២៣.ភសរ.សសរ/២០

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារក្រសួងយុត្តិធម៌ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ និងការងារទាក់ទងនឹងវត្តតាងបទល្មើសគ្រឿងញៀន

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៧៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមការចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ ១._**

បង្កើតក្រុមការងារក្រសួងយុត្តិធម៌ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ និងការងារទាក់ទងនឹងវត្ថុតាងបទល្មើសគ្រឿងញៀន ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **ព្រហ្ម សិទ្ធរ៉ា** | រដ្ឋលេខាធិការ | ប្រធាន |
| ២. | ឯកឧត្តម | **ម៉ុក ម៉ាន់នី** | អនុរដ្ឋលេខាធិការ | អនុប្រធានប្រចាំការ |
| ៣. | លោក | **ពេញ មិថុល** | អគ្គនាយករងនៃអគ្គនាយដ្ឋាន | |



មហាវិថីសម្តេចសុធារស,ខ័ណ្ឌដូនពេញ,រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

| | | | | | |
|---|---|---|---|---|---|
| | | | | កិច្ចការអយ្យការ និងព្រហ្មទណ្ឌ | អនុប្រធាន |
| ៤. | លោក | យ៉ម | ផារ៉ូត | នាយករងខុទ្ទកាល័យ | សមាជិក |
| ៥. | លោក | ម៉ែន | ចំណាន | ប្រធាននាយកដ្ឋាន បុកសុប បណ្ណសារ និងព័ត៌មានវិទ្យា | សមាជិក |
| ៦. | លោក | ហ៊ឹម | ឌិចគេណា | អនុប្រធាននាយកដ្ឋានអាជ្ញាសាលា | សមាជិក |
| ៧. | លោក | ជា | សុខរ័ត្ន | អនុប្រធានការិយាល័យ សន្តិសុខ និងសណ្តាប់ធ្នាប់ | លេខាធិការ។ |

**ប្រការ ២._**

ក្រុមការងារក្រសួងយុត្តិធម៌ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ និងការងារទាក់ទងនឹងវត្ថុតាងបទល្មើសគ្រឿងញៀន មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ចុះតាមដានសំណុំរឿងបទល្មើសគ្រឿងញៀនតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីពន្លឿននីតិវិធីចំណាត់ការរឿងក្តី និងពន្លាតនីតិវិធីឈានដល់ការបង្ក្រាបបទល្មើសសម្អាតប្រាក់ និងស្វែងរកទ្រព្យសម្បត្តិ និងផលដែលកើតចេញពីបទល្មើសគ្រឿងញៀនរបស់ជនល្មើស ស្របតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- ចុះតាមសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដើម្បីប្រមូល និងចាត់ចែងរក្សាទុកជាបណ្តោះអាសន្ននូវរូបិយវត្ថុជាតិ និងរូបិយប័ណ្ណអន្តរជាតិដែលត្រូវបានសម្រេចរឹបអូសជាសម្បត្តិរដ្ឋ ដោយដីកាសម្រេច ឬដោយសាលក្រមដែលមិនទាន់ចូលជាស្ថាពរ រង់ចាំរហូតដល់បញ្ចប់នីតិវិធីនៅតុលាការ ដើម្បីចាត់ចែងបន្តតាមនីតិវិធីជាធរមាន
- ចុះតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីពន្លឿននីតិវិធីនៃចំណាត់ការរឿងក្តី និងចេញសាលក្រម ឬសាលដីកាស្ថាពរ ដែលសម្រេចរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ នូវទ្រព្យសម្បត្តិដែលកើតចេញពីបទល្មើសគ្រឿងញៀនរបស់ជនល្មើស
- ចុះតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីប្រមូលសាលក្រម សាលដីកាស្ថាពរ ដែលបានសម្រេចរឹបអូសជាសម្បត្តិរដ្ឋនូវវត្ថុតាង មធ្យោបាយ និងទ្រព្យសម្បត្តិផ្សេងៗ ពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ជូនគណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិ ដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដើម្បីចាត់ចែងតាមនីតិវិធី
- សហការជាមួយលេខាធិការដ្ឋាននៃគណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចុះតាមសាលាដំបូងរាជធានី-ខេត្ត ធ្វើការពិនិត្យ និងវាយតម្លៃលើវត្ថុតាងមធ្យោបាយ និងទ្រព្យសម្បត្តិផ្សេងៗ ពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដែលរឹបអូសជា

ទ្រព្យសម្បត្តិរដ្ឋតាមអំណាចសាលក្រម ឬសាលដីកាស្ថាពរ ក្នុងគោលបំណងដើម្បីចាត់ចែង ឬលក់ឡាយឡុងយកថវិកាដាក់ចូលទៅក្នុងមូលនិធិរបស់អាជ្ញាធរជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

- ចុះតាមសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដើម្បីប្រមូលវត្ថុតាងជាគ្រឿងញៀនដែលស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេត ស៊ើបសួរ និងជំនុំជម្រះ និងស្នើសុំគោលការណ៍សម្រេចពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីធ្វើការបំផ្លាញចោល ស្របតាមបញ្ញត្តិនៃមាត្រា៨៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ ៣._**

សេចក្តីសម្រេចលេខ ០៣៨ កយ.សសរ/១៨ ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៨ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន ប្រធានគ្រប់អង្គភាពចំណុះក្រសួងយុត្តិធម៌ សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៦កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០២០

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៤
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ